**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

លេខៈ ៩៣ ស.ស.រ

# សេចក្តីសម្រេច

## ស្តីពីការកែសម្រួលសមាសភាពសមាជិកក្រុមប្រឹក្សាភិបាលជាតិ គ្រប់គ្រងគំរោងជំនួយផ្នែកព្រហ្មទណ្ឌនិងយុត្តិធម៌នៅកម្ពុជា

## រាជរដ្ឋាភិបាលកម្ពុជា

-បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស រកត ១១៩៨ ៧២ ចុះថ្ងៃទី៣០ ខែវិច្ឆកា ឆ្នាំ ១៩៩៨ ស្តីពី ការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២ នស ៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រមលេខ នស រកម ០១៩៦ ០៨ ចុះថ្ងៃទី ២៤ ខែមករា ឆ្នាំ ១៩៩៦ ប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ

-បានឃើញព្រះរាជក្រមលេខ នស រកម ០១៩៦ ០៤ ចុះថ្ងៃទី ២៤ ខែមករា ឆ្នាំ ១៩៩៦ ប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើតក្រសួងយុត្តិធម៌

-យោងអនុស្សារណៈយោគយល់រវាងរាជរដ្ឋាភិបាលកម្ពុជា និងរដ្ឋាភិបាលអូស្ត្រាលី ចុះថ្ងៃទី២៨ ខែវិច្ឆិកា ឆ្នាំ១៩៩៤

-យោងអនុស្សារណៈស្តីពីការរៀបចំចាត់ចែង ទាក់ទងនឹងគំរោងជំនួយផ្នែកព្រហ្មទណ្ឌ និងយុត្តិធម៌នៅកម្ពុជា ដំណាក់កាលទី៣ ចុះថ្ងៃទី១២ ខែមិនា ឆ្នាំ២០០៧

-យោងសេចក្តីសម្រេចលេខ២៥ សសរ ចុះថ្ងៃទី២៣ ខែឧសភា ឆ្នាំ២០០៧ របស់រាជរដ្ឋាភិបាល ស្តីពីការបង្កើតក្រុមប្រឹក្សាភិបាលជាតិគ្រប់គ្រងគំរោងជំនួយផ្នែកព្រហ្មទណ្ឌ និង យុត្តិធម៌នៅកម្ពុជា

-តាមសំណើររបស់ប្រធានក្រុមប្រឹក្សាភិបាលជាតិគ្រប់គ្រងគំរោងជំនួយផ្នែកព្រហ្មទណ្ឌនិងយុត្តិធម៌នៅកម្ពុជា

## សំរេច

**ប្រការ១.-** ត្រូវបានកែសម្រួលសមាសភាពក្រុមប្រឹក្សាភិបាលជាតិគ្រប់គ្រងគំរោងជំនួយផ្នែកព្រហ្មទណ្ឌ និងយុត្តិធម៌នៅកម្ពុជា គណៈកម្មការប្រតិបត្តិ ក្រុមពិគ្រោះយោបល់ និងប្រធានលេខាធិការដ្ឋាន ទបសស ខេត្ត ដែលមានសមាសភាពដូចខាងក្រោម ៖

១-ឯកឧត្តម **អ៊ិត រ៉ាឌី** អនុរដ្ឋលេខាធិការក្រសួងយុត្តិធម៌ជាអនុប្រធានក្រុមប្រឹក្សាភិបាលជាតិគ្រប់គ្រងគំរោង ជំនួយផ្នែក ព្រហ្មទណ្ឌ និង យុត្តិធម៌នៅកម្ពុជា និង ជាអនុប្រធានគណៈកម្មការប្រតិបត្តិ ជំនួសឯកឧត្តម **អ៊ី ជន** ដែលបានទទួលមរណភាព

២-ឯកឧត្តម **ឈុន សុីរុន** អភិបាលខេត្តកណ្តាល ជាសមាជិកគណៈកម្មាការប្រតិបត្តិជំនួសឯកឧត្តម **ឃឹម បូរ** ដែលត្រូវទទួលភារកិច្ចថ្មី

៣-លោក **អ៊ូ សំអួន** អភិបាលរងខេត្តកណ្តាលជាសមាជិកក្រុមពិគ្រោះយោបល់ និងជាប្រធានលេខាធិការដ្ឋាន ទបសស ខេត្ត ( ជនបង្គោលផ្នែក ទបសស ខេត្ត ) ជំនួសលោក **ចេង ញ៉ារ៉ន់** ដែលត្រូវទទួលភារកិច្ចថ្មី

៤-លោក **ពៅ ម៉ុនធឿន** ប្រធាននាយកដ្ឋានកិច្ចការព្រហ្មទណ្ឌ នៃក្រសួងយុត្តិធម៌ ជាសមាជិកបន្ថែមនៅក្នុងគណៈកម្មាការប្រតិបត្តិ

៥- លោក **ចេង ញ៉ារ៉ន់** មន្ត្រីក្រសួងមហាផ្ទៃ ជាសមាជិកបន្ថែមនៅក្នុងក្រុមពិគ្រោះយោបល់

**ប្រការ២.-** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ក្រសួងស្ថាប័នពាក់ព័ន្ធ ប្រធានក្រុមប្រឹក្សាភិបាលជាតិគ្រប់គ្រងគំរោងជំនួយផ្នែកព្រហ្មទណ្ឌ និង យុត្តិធម៌នៅកម្ពុជា និងសាម៉ីខ្លួនដូចមានចែងក្នុងប្រការ១ ត្រូវអនុវត្តតាមសេចក្តីសំរេចនេះអោយមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ, ថ្ងៃទី១៧ ខែ ១០ ឆ្នាំ ២០០៧

ស ខេង

**<u>កន្លែងទទួល៖</u>**

- -ក្រសួងព្រះបរមរាជវាំង
- -អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- -អគ្គលេខាធិការដ្ឋានរដ្ឋសភា
- -ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- -ដូចប្រការ១
- -ឯកសារ-កាលប្បវត្តិ